ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិគន្ធបុប្ផាកម្ពុជា
លេខ :................ម.គ.ក........

*ថ្ងៃ ចន្ទ ៤ កើត ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការប្រគល់-ទទួលថវិកាឧបត្ថម្ភប្រចាំឆ្នាំរបស់កាកបាទក្រហមកម្ពុជា ជូនមូលនិធិគន្ធបុប្ផាកម្ពុជា

នារសៀលថ្ងៃចន្ទ ៤ កើត ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២០, នៅទីស្តីការកាកបាទក្រហមកម្ពុជា, **លោកជំទាវ អាន្នី សុខអាន** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា បានជួបពិភាក្សា និងប្រគល់ថវិកាឧបត្ថម្ភប្រចាំឆ្នាំ២០២០ ចំនួន **១ 000 000 (មួយលាន)ដុល្លារអាមេរិក** របស់កាកបាទក្រហមកម្ពុជា ជូនក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា ដែលដឹកនាំដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា ។

ក្នុងឱកាសនោះ **លោកជំទាវ អាន្នី សុខអាន** បានពាំនាំនូវការសួរសុខទុក្ខពីសំណាក់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងបានសម្តែងនូវសេចក្តីសោមនស្សរីករាយ ក្នុងការជួបពិភាក្សាជាមួយក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា ។ **លោកជំទាវ** ក៏បានលើកឡើងពីសកម្មភាពសប្បុរសធម៌របស់កាកបាទក្រហមកម្ពុជា ដែលបានចុះជួយដល់បណ្តាប្រជាជនរងគ្រោះ និងមានការខ្វះខាតផ្នែកជីវភាពរស់នៅ ជាពិសេសក្នុងខណៈពេលដែលជំងឺកូវីដ-១៩ បាន និងកំពុងរាតត្បាត ក្នុងនោះក៏រួមមានការបន្តជួយឧបត្ថម្ភថវិកាប្រចាំឆ្នាំជូនមូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីជួយសង្គ្រោះជីវិតកុមារនៅកម្ពុជា ផងដែរ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសម្តែងនូវការថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលបានសួរសុខទុក្ខ និងតែងតែមានសមានចិត្ត ព្រមទាំងយកចិត្តទុកដាក់ខ្ពស់ ដល់សុខទុក្ខរបស់ប្រជាជន ជាពិសេសកុមារនៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូន **លោកជំទាវ អាន្នី សុខអាន** អំពីស្ថានភាពប្រតិបត្តិការ និងហិរញ្ញវត្ថុ របស់មូលនិធិគន្ធបុប្ផាកម្ពុជា ចាប់តាំងពីមូលនិធិត្រូវបាន ដាក់ឱ្យដំណើរការជាផ្លូវការ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន និងបានលើកឡើងផងដែរអំពីផលប៉ះពាល់ដែលបាន និងកំពុងកើតមានឡើងដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ដូចជាការថយចុះនៃទំហំបរិច្ចាគពីសំណាក់សប្បុរសជននានា ជាពិសេសផលប៉ះពាល់ដោយសារការធ្លាក់ចុះនៃភ្ញៀវទេសចរណ៍អន្តរជាតិនៅខេត្តសៀមរាប ដែលធ្វើឱ្យការឧបត្ថម្ភប្រចាំត្រីមាសរបស់គ្រឹះស្ថានអង្គរជូនមូលនិធិ ពីការកាត់កម្រៃសំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ មានការថយចុះ ។ ទោះយ៉ាងណា ការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា និងកាកបាទក្រហមកម្ពុជាសម្រាប់មូលនិធិ គឺពុំមានការថយចុះនោះទេ បើទោះបីជាការរាតត្បាតនៃជំងឺកូវីដ-១៩ បាន និងកំពុងមានផលអវិជ្ជមានចំពោះសេដ្ឋកិច្ច និងសង្គមកម្ពុជា ក៏ដោយ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏លើកឡើងអំពីការបាត់បង់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត Beat Richner ស្ថាបនិកមន្ទីរពេទ្យគន្ធបុប្ផា និងលោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត Peter Studer អតីតអនុប្រធានក្រុមប្រឹក្សាភិបាល និងជានាយកប្រតិបត្តិមូលនិធិគន្ធបុប្ផាស្វីស ផងដែរ ដែលលោកទាំងពីរបានលះបង់កម្លាំងកាយចិត្ត ដើម្បីបុព្វហេតុកុមារនៅកម្ពុជា ។

**លោកជំទាវ អាន្នី សុខអាន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** និងមូលនិធិគន្ធបុប្ផាកម្ពុជា ចំពោះកិច្ចខិតខំប្រឹងប្រែង និងការយកចិត្តទុកដាក់ខ្ពស់ចំពោះ មន្ទីរពេទ្យគន្ធបុប្ផា ។ **លោកជំទាវ** ក៏បានថ្លែងរំលែកទុក្ខដ៏ក្រៀមក្រំចំពោះមរណៈភាព របស់លោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត Beat Richner និង Peter Studer និងបានថ្លែងអំណរគុណដ៏វិសេសវិសាលចំពោះការលះបង់របស់លោកទាំងពីរ ដើម្បីបុព្វហេតុកុមារនៅកម្ពុជា នាពេលកន្លងមក ។ **លោកជំទាវ** ក៏បានផ្តាំផ្ញើសួរសុខទុក្ខដល់លោកគ្រូ អ្នកគ្រូពេទ្យទាំងអស់ ដែលបាន និងកំពុងបំពេញបេសកកម្មពិនិត្យ ពិគ្រោះ និងព្យាបាលជំងឺជូនកុមារនៅកម្ពុជា ប្រកបដោយគុណភាព និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការកោតសរសើរដ៏ខ្ពង់ខ្ពស់ចំពោះការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលបានធ្វើឱ្យកាកបាទក្រហមកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំង និងបានក្លាយជាស្ថាប័នមនុស្សធម៌ដ៏រឹងមាំមួយនៅព្រះរាជាណាចក្រកម្ពុជា និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **លោកជំទាវ អាន្នី សុខអាន** ដែលបានចំណាយពេលវេលាក្នុងការជួបពិភាក្សា និងប្រគល់ថវិកាឧបត្ថម្ភប្រចាំឆ្នាំ២០២០ ចំនួន **១ 000 000 (មួយលាន) ដុល្លារអាមេរិក** របស់កាកបាទក្រហមកម្ពុជាជូនក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា ដែលប្រគល់បន្តដល់មន្ទីរពេទ្យគន្ធបុប្ផា ។